# ១៨- រឿង បុរសកម្សត់សង់ខ្ទមក្បែរផ្ទះសេដ្ឋី ធ្វើត្រាប់សេដ្ឋី

មាននិទានមួយថា : មានបុរសប្ដីប្រពន្ធនឹងកូនស្រីមួយជាអ្នកលំបាក កម្សត់ទុគ៌ត រកព្រឹកបានស៊ីតែព្រឹក រកល្ងាចបានស៊ីតែល្ងាច ពុំមានទ្រព្យរបស់អម្រស់អម្រអ្វីឡើយ ទើបបុរសប្ដីប្រពន្ធនោះគិតគ្នាថា “ លំនៅយើងសព្វថ្ងៃនេះលំបាកណាស់ មកយើងទៅរកលោកឯណាមានទ្រព្យសម្បត្តិច្រើនយើងទៅនៅខាងលោក លបមើលដំណើរលោក ៗ ធ្វើការម្ដេចខ្លះបានជាមានទ្រព្យរបស់ច្រើន ” ។ អ្នកទាំង ២ នាក់ប្ដីប្រពន្ធនោះ គិតគ្នាដូច្នោះហើយ ក៏រុះរើខ្ទមទៅសង់នៅក្បែរខាងផ្ទះសេដ្ឋី ។ សេដ្ឋីនោះឯង តែងប្រើខ្ញុំឲ្យទៅជួញប្រែ ធ្វើស្រែចម្ការ បានទ្រព្យរបស់បំពេញឃ្លាំងពុំដែលដាច់ឡើយ ។ ឯបុរសប្ដីប្រពន្ធ និងកូនមួយ បានធ្វើត្រាប់តាមអំពីការទាំងអម្បាលនោះរបស់សេដ្ឋី ។ ចំណេរលង់ទៅ កើតផលប្រយោជន៍ បានទ្រព្យរបស់ច្រើន ទើបបុរសនោះដឹងគុណមហាសេដ្ឋី ហើយក៏យកមាសមួយស្លឹក់មកជូនមហាសេដ្ឋី ។ មហាសេដ្ឋី ដណ្ដឹងថា “ហេតុម្ដេចបានជាថៅយកមាសឲ្យអញ ?” ។ បុរសប្រាប់ថា “ត្បិតខ្ញុំបាទនេះ ជាអ្នកកម្សត់ទុគ៌ត ខ្ញុំបាទរុះរើខ្ទមមកនៅក្បែរផ្ទះលោក ខ្ញុំបាទមើលឃើញលោក តែងប្រើអស់ខ្ញុំកំដរឲ្យទៅជួញប្រែធ្វើស្រែកាប់ចម្ការឲ្យបានជាទ្រព្យរបស់មក ខ្ញុំបាទប្ដីប្រពន្ធនិងកូន មួយធ្វើត្រាប់អំពីការទាំងនោះតាមលោក ក៏បានជាអ្នកមានទ្រព្យរបស់លោះខ្ញុំកំដរ ទិញគោក្របីបានប្រើជាច្រើន ទើបខ្ញុំបាទរលឹកដល់គុណលោក ហើយខ្ញុំបាទយកមាសមួយស្លឹក់មកជូនលោកហោង” ។ សេដ្ឋីថា “ថៅបានទ្រព្យអម្បាលនេះ អញស្មានថា ថៅបានពីណា បើថៅបានត្បិតថៅធ្វើតាមចំណេះអញតែងធ្វើដូច្នេះហើយ ចូរថៅទៅយកទ្រព្យអម្បាលនោះមកឲ្យអញ ៗ នឹងចែករំលែកឲ្យថៅខ្លះ” ។ បុរសនោះឆ្លើយថា “ ត្បិតខ្ញុំព្រះបាទធ្វើអំពីការត្រាប់តាមលោក បានទ្រព្យរបស់អម្បាលនេះ ខ្ញុំបាទរលឹកគុណលោក ទើបខ្ញុំយកមាសមួយស្លឹក់មកជូន ខ្ញុំបាទយល់ថា លោកនឹងយកតែប៉ុណ្ណោះ បើលោកប្រើខ្ញុំបាទឲ្យទៅយករបស់ខ្ញុំបាទទាំងអស់មក ខ្ញុំបាទពុំយកមកជូនទេ” ។ សេដ្ឋី និងបុរសនោះប្រកែកដណ្ដើមទ្រព្យគ្នាទៅវិញទៅមក ទើបសេដ្ឋីនាំបុរសនោះទៅដល់ថៅក្រមជំនុំពិចារណា ថៅក្រមជំនុំជម្រះរឿងនោះពុំបាន ទើបនាំសេដ្ឋីនិងបុរសនោះទៅគាល់ព្រះមហាក្សត្រ ។ បុរសនោះក្រាបបង្គំទូលថា “ ខ្ញុំព្រះបាទអម្ចាស់នេះនៅក្បែរផ្ទះសេដ្ឋីនេះ ខ្ញុំព្រះបាទអម្ចាស់យល់គាត់តែងប្រែខ្ញុំកំដរគាត់ឲ្យទៅជួញប្រែ ធ្វើស្រែចម្ការបានទ្រព្យជាផលប្រយោជន៍ផ្ទាល់ខ្លួនគាត់ ហើយខ្ញុំព្រះបាទអម្ចាស់ប្ដីប្រពន្ធនិងកូនមួយ យកខ្លួនធ្វើនូវអំពើការត្រាប់តាមគាត់ បានទ្រព្យរបស់លោះខ្ញុំទិញគោក្របី ទើបខ្ញុំព្រះបាទអម្ចាស់គិតដល់គុណគាត់ហើយយកមាសមួយស្លឹក់ទៅឲ្យគាត់ ៗ ពុំយកតែមាសមួយស្លឹក់នេះឡើយ គាត់ប្រើខ្ញុំព្រះបាទអម្ចាស់ទៅយកទ្រព្យរបស់ មាសប្រាក់ មកឲ្យគាត់ទាំងអស់ហើយគាត់នឹងចែកឲ្យខ្ញុំព្រះបាទអម្ចាស់វិញ ខ្ញុំព្រះបាទអម្ចាស់ពុំយកទ្រព្យទាំងនោះមកឲ្យគាត់ ទើបគាត់នាំខ្ញុំព្រះបាទអម្ចាស់ទៅប្ដឹងថៅក្រមឲ្យជំនុំជម្រះពិចារណា ថៅក្រមជំនុំពុំបាន សេចក្ដីទាំងនេះពុំចេរ សូមទ្រង់ព្រះចិន្ដាពិចារណាឲ្យខ្ញុំព្រះបាទអម្ចាស់ហោង” ។ ទើបព្រះមហាក្សត្រទ្រង់ត្រាស់ដណ្ដឹងទៅសេដ្ឋីថា “ ម្នាលព្រះស្ដែង ! ដំណើរព្រះស្ដែងតើដូចម្ដេច ? ” ។ សេដ្ឋីក្រាបទូលថា “ ដំណើរសេដ្ឋីនៃខ្ញុំព្រះបាទអម្ចាស់នេះ ដូចពាក្យបុរសក្រាបទូលនេះហោង” ។ ព្រះមហាក្សត្រទ្រង់យល់ថា សេដ្ឋីលោភមែនពិត ទើបព្រះអង្គមានព្រះបន្ទូលដណ្ដឹងថា “ ម្នាលសេដ្ឋី ! ព្រះស្ដែងមានកូនឬឥតកូន” ។ សេដ្ឋីក្រាបបង្គំទូលថា “ ខ្ញុំព្រះបាទអម្ចាស់មានកូនប្រុសមួយ ” ។ ទើបព្រះអង្គមានព្រះបន្ទូលដណ្ដឹងទៅបុរសនោះវិញថា ព្រះស្ដែងមានកូនឬឥតកូន ?” ។ បុរសក្រាបបង្គំទូលថា “ខ្ញុំព្រះបាទអម្ចាស់មានកូនស្រីមួយ” ។ ព្រះមហាក្សត្រមានព្រះបន្ទូលថា “ម្នាលព្រះស្ដែងទាំង ២ អើយ ! ម៉្លេះហើយកុំ

ខឹងនឹងគ្នាទៅវិញទៅមក អញឲ្យព្រះស្តែងទាំង ២ ចងពន្ធនឹងគ្នា ឲ្យកូនប្រុសសេដ្ឋីនិងកូនស្រីអ្នកជាប្តីប្រពន្ធនឹងគ្នាទៅ ដើម្បីឲ្យទ្រព្យរបស់ព្រះស្តែងទាំង ២ នាក់មូលទៅលើកូននោះឯង ។ សេដ្ឋីនិងបុរសស្តាប់ព្រះបន្ទូលដូច្នោះហើយ ចូលចិត្តក៏ក្រាបថ្វាយបង្គំលាទៅលំនៅអាត្មា រិះរកប្រដាប់ការកូនទាំង ២ សម្រេចដោយប្រការអម្បាលនេះហោង ។